# លិខិតជូនពរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសចំរើនជន្មាយុគំរប់ ៥៨ វស្សា ឈានចូល ៥៩ វស្សា នាថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០៩
## និងក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំ ឆ្លូវ ឯកស័ក ព.ស ២៥៥៣

**សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត និងជាទីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត !**

ក្នុងឱកាសបុណ្យចំរើនជន្មវស្សារបស់សម្តេចនាយករដ្ឋមន្ត្រី គំរប់ *៥៨* វស្សា ឈានចូល *៥៩* វស្សា នាថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ និងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំឆ្លូវ ឯកស័ក ព.ស ២៥៥៣ ក្នុងនាមថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគោរពសុំការអនុញ្ញាតប្រសិទ្ធិពរជ័យសិរីមង្គលដ៏បវរមហាប្រសើរបំផុត ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។ សូមសម្តេចនាយករដ្ឋមន្ត្រីប្រកបដោយសុខភាពល្អបរិបូរណ៍ជានិច្ច មានជន្មាយុយឺនយូរ សុភមង្គលនិងចម្រុងចម្រើនក្នុងគ្រួសារ និងសម្រេចបានមហាជោគជ័យធំថ្មីៗទៀត ក្នុងបេសកកម្មជាតិដ៏ឧត្តុង្គឧត្តមរបស់សម្តេចនាយករដ្ឋមន្ត្រី ដើម្បីជាគុណប្រយោជន៍សំរាប់សុខមាលភាពរបស់ប្រជាជនកម្ពុជាទាំងមូល និង ដើម្បីជាគុណប្រយោជន៍សំរាប់កិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជា ។

យើងខ្ញុំសូមឆ្លៀតយកឱកាសដ៏នក្ខត្តឫក្សនេះ ដើម្បីសម្តែងនូវការកោតស្ញប់ស្ញែង និង កតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះស្នាដៃនៃការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ក្នុងបីទសវត្សកន្លងមក ។ យ៉ាងណាមិញព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃនយោបាយ **ឈ្នះ-ឈ្នះ** របស់សម្តេចនាយករដ្ឋមន្ត្រី នោះគឺ សន្តិភាពពេញលេញ ឯកភាពទឹកដី ជាននយោបាយ ជាស្ថាប័ន ជារូបវន្ត យ៉ាងពេញលេញ ជាមួយស្ថេរភាពនយោបាយ សន្តិសុខនិងសណ្តាប់ធ្នាប់សង្គម និង ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ មានបរិការណ៍អំណោយផលគ្របដណ្តប់យ៉ាងនេះ ការអនុវត្ត **«យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២»** របស់សម្តេចនាយករដ្ឋមន្ត្រី ច្បាស់ជាបានសម្រេចជោគជ័យ ទោះបីបច្ចុប្បន្នកម្ពុជា កំពុងទទួលឥទ្ធិពលអវិជ្ជមានពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសាកលលោកក៏ដោយ ។ កំណាត់ការរបស់សម្តេចនាយករដ្ឋមន្ត្រី សំរាប់ស្រោចស្រង់វិស័យកាត់ដេរ វិស័យទេសចរណ៍ និងវិស័យសំណង់ និងអចលនទ្រព្យ ច្បាស់ជាកាត់បន្ថយបាន នូវផលប៉ះពាល់មកពីខាងក្រៅ ។ ដោយឡែក ចំណាត់ការនៃពិពិធកម្មសេដ្ឋកិច្ចរបស់សម្តេចនាយករដ្ឋមន្ត្រី តាមរយៈការអភិវឌ្ឍវិស័យកសិកម្ម និង វិស័យកសិ-ឧស្សាហកម្មគ្រប់ជ្រុងជ្រោយនឹងទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា និង ទ្រទ្រង់ជីវភាពរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស ។ វិបុលភាពនៃប្រទេស និងជីវភាពសមរម្យរបស់ប្រជាជន ជាសក្ខីកម្មដ៏ប្រត្យក្ស នៃការធានាជាមូលដ្ឋាន នៃការគោរពសិទ្ធិមនុស្ស ។ ព្រមជាមួយនេះ ចលនាការ ដែលសម្តេចនាយករដ្ឋមន្ត្រី បានបង្កើតឡើងសំរាប់ការអភិវឌ្ឍ និងកំណែទំរង់ទាំងឡាយ មាន **កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ**

**ការអភិវឌ្ឍវិស័យឯកជន** និងការកសាង **អភិបាលកិច្ច** នៃផ្នែកសាធារណៈ ដែលមានរួមបញ្ចូលនូវ **កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់រដ្ឋបាល** និង **កំណែទម្រង់ប្រព័ន្ធច្បាប់ និង តុលាការ** ទន្ទឹមនឹងការកសាង **អភិបាលកិច្ច** របស់ផ្នែកសាជីវកម្មឯកជន នឹងធ្វើឱ្យប្រសើរឡើងថែមទៀតនូវបរិស្ថានធុរកិច្ច និងការវិនិយោគ តាមរយៈការសម្រួលពាណិជ្ជកម្ម និង ការលើកកំពស់ការចូលរួមរបស់វិស័យឯកជនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ។ ប្រការនេះ នឹងលើកទឹកចិត្តឱ្យយើងខ្ញុំទាំងអស់គ្នា ប្ដេជ្ញាបង្កើនថាមពលក្នុងការបំពេញភារកិច្ច តាមមុខសញ្ញារៀងៗខ្លួន ដោយប្រកាន់សីលធម៌ស្អាតស្អំ ប្រកាន់មនសិការវិជ្ជាជីវៈ និង ស្វះស្វែងសម្រេចឱ្យបាននូវប្រសិទ្ធភាពការងារខ្ពស់ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីធ្វើឱ្យគោលដៅ ប្រកបដោយមហិច្ឆិតានៃ **«យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី២»** របស់សម្ដេចនាយករដ្ឋមន្ត្រី បានសម្រេច ទោះភព្ទាសត្បានុម៉ត ពីក្រៅប្រទេស មិនអំណោយផលក៏ដោយ ។ យ៉ាងនេះ ទើបសក្ដិសមនឹងគុណូបការៈដ៏ធំធេងទាំងឡាយរបស់សម្ដេចនាយករដ្ឋមន្ត្រី ចំពោះប្រទេសជាតិកន្លងមក ។

មួយវិញទៀត យើងខ្ញុំសូមឆ្លៀតឱកាសដ៏ប្រសើរនេះ រំលឹកដោយកតញ្ញូនូវគុណមំណាច់ដ៏ធំធេងរបស់លោកជំទាវ **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលមានទឹកចិត្តមោះមុត សណ្ដោសប្រណីដំណើរការសកម្មភាពមនុស្សធម៌ ដោយធ្វើការឥតខ្លាចនឿយហត់ ដូចភ្លៀងរលឹម ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងការលំបាក ប្រចាំថ្ងៃរបស់ប្រជាជន និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ទាំងជើងគោក ជើងទឹក និង អាកាស ព្រមទាំងយុទ្ធជនពលីពិការ ។ ក្រសែភ្នែកញញឹមរបស់ជនងាយរងគ្រោះ និងជនរងគ្រោះ ជារង្វាស់រង្វាល់នៃជំរៅនៃក្ដីសង្ឃឹមរបស់ជនទាំងនោះ ដែលបានទទួលការប្រោសប្រណីពីលោកជំទាវ ។

សូមសម្ដេចនាយករដ្ឋមន្ត្រី លោកជំទាវ និង ក្រុមគ្រួសារទាំងមូល សម្រេចបានជានិច្ចនូវជ័យសិរីមង្គល វិបុលសុខគ្រប់ប្រការ និងជាភិយ្យោភាព ។

សូមសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ទឹកចិត្តស្រឡាញ់យ៉ាងជ្រាលជ្រៅ និងភក្ដីភាពឥតងាករេពីយើងខ្ញុំ

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០០៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

គាត ឈន់